**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខៈ២៦៤.អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការកែសម្រួលសាលាកងទ័ពជើងទឹក ទៅជាវិទ្យាស្ថានកងទ័ពជើងទឹក
## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០១ ស្តីពីការកែសម្រួលតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ

## សម្រេច

**មាត្រា១ .-**

ត្រូវបានកែសម្រួលតម្លើងកម្រិតសាលាកងទ័ពជើងទឹក ទៅជាវិទ្យាស្ថានកងទ័ពជើងទឹក។

**មាត្រា២ .-**

វិទ្យាស្ថានកងទ័ពជើងទឹកមានតួនាទីធ្វើជាសេនាធិការជូនមេបញ្ជាការកងទ័ពជើងទឹក លើការងារបណ្តុះបណ្តាលធនធានមនុស្ស ជំនាញបញ្ជាការនាវា បញ្ជាការសេនាធិការ ថ្នាក់បរិញ្ញាប័ត្ររង បរិញ្ញាប័ត្រ និងបរិញ្ញាប័ត្រជាន់ខ្ពស់ និងមានភារកិច្ចដូចខាងក្រោម៖

- បណ្តុះបណ្តាលបញ្ជាការសេនាធិការកងទ័ពជើងទឹក
- បណ្តុះបណ្តាលនាយនាវីជំនាញបញ្ជាការនាវាកម្រិតបឋម
- បណ្តុះបណ្តាលយោធិនជំនាញបច្ចេកទេស កងទ័ពជើងទឹក

- បណ្តុះបណ្តាលយោធិនជំនាញការពារកោះឆ្នេរ
- បណ្តុះបណ្តាលនិងបំប៉នបណ្តាជំនាញជើងទឹក តាមសេចក្តីត្រូវការជាក់ស្តែងរបស់កងទ័ពជើងទឹក
- ទំនាក់ទំនង និងសហការជាមួយស្ថាប័ន ចំណុះក្រសួងការពារជាតិ អគ្គបញ្ជាការ និងបណ្តាកងឯកភាព នៃកងយោពលខេមរភូមិន្ទ ដើម្បីធានាជម្រុញការងារហ្វឹកហ្វឺន បណ្តុះបណ្តាល ឲ្យមាននិរន្តរភាព
- ទំនាក់ទំនងសហការជាមួយក្រសួងអប់រំយុវជន និងកីឡា និងស្ថាប័នរដ្ឋពាក់ព័ន្ធរៀបចំកម្មវិធីសិក្សាឲ្យមានសមមូលតាមកម្រិតសញ្ញាប័ត្រ។

**មាត្រា៣ .-**

តួនាទីភារកិច្ចរចនាសម្ព័ន្ធ និងក្របខ័ណ្ឌចាត់តាំងលម្អិតអាស្រ័យដោយក្រសួងការពាជាតិកំណត់។

**មាត្រា៤ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយ នឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៥ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ១០រោច ខែ បុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៧ ខែមករា ឆ្នាំ២០២២

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

**សម្តេចពិជ័យសេនា ទៀ បាញ់**

**កន្លែងទទួល**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា ៥
-រាជកិច្ច
-ឯកសារកាលប្បវត្តិ